ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

ថ្ងៃ.ច័ន្ទ..៤កើត..ខែ.ចេត្រ..ឆ្នាំឆ្លូវ..ត្រីស័ក.ព.ស.២៥៦៥.

លេខ..០៣៣...អបស.មព

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ មេសា ឆ្នាំ២០២២.

# រដ្ឋមន្ត្រីក្រសួងសុខាភិបាល

## ជម្រាបមក

## លោក លោកស្រី ជាម្ចាស់សេវាពិនិត្យព្យាបាលជំងឺឯកជនទាំងអស់

**កម្មវត្ថុ៖** ស្តីពីការក្រើនរំឭកចុងក្រោយទៅដល់គ្រប់ម្ចាស់សេវាពិនិត្យព្យាបាលជំងឺឯកជនទាំងអស់ ក្នុងការអនុវត្តវិធានការក្នុងការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ។

**យោង៖**
- ព្រះរាជក្រមលេខ នស/រកម/០៣២១/០០៤ ចុះទី១១ ខែមីនា ឆ្នាំ២០២១ ប្រកាសឱ្យប្រើច្បាប់ ស្តីពីវិធានការទប់ស្កាត់ ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត។
- អនុក្រឹត្យលេខ ៣៧ អនក្រ.បក ចុះទី១២ ខែមីនា ឆ្នាំ២០២១ ស្តីពីវិធានការសុខាភិបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត។
- លិខិតលេខ ១០៣ អបស.មព ចុះទី២៥ ខែធ្នូ ឆ្នាំ២០២០ ស្តីពីការជំរុញកិច្ចសហការពីម្ចាស់សេវាពិនិត្យព្យាបាលជំងឺឯកជន ក្នុងការបញ្ជូនអ្នកសង្ស័យជំងឺកូវីដ-១៩ ពីមូលដ្ឋានខ្លួនទៅមន្ទីរពេទ្យរដ្ឋនៅទូទាំងខេត្ត និងមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀតនៅរាជធានីភ្នំពេញ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើនេះ ក្រសួងសុខាភិបាលសូមជម្រាបជូន **លោក លោកស្រី ដែលជាម្ចាស់សេវាពិនិត្យព្យាបាលជំងឺឯកជនទាំងអស់** ឱ្យបានជ្រាបថា រយៈកាលកន្លងមក ក្រសួងសុខាភិបាលបានធ្វើសេចក្តីណែនាំរួចមកហើយ ស្តីអំពីវិធានការក្នុងការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ជាពិសេស គឺហាមមិនអនុញ្ញាតឱ្យកន្លែងពិនិត្យព្យាបាលជំងឺឯកជនធ្វើការពិនិត្យព្យាបាលអ្នកជំងឺដែលសង្ស័យថាជាជំងឺកូវីដ-១៩ ជាដាច់ខាត។ ដើម្បីទប់ស្កាត់កុំឱ្យមានការរាលដាលនៃជំងឺកូវីដ-១៩ ទ្រង់ទ្រាយធំនៅក្នុងសហគមន៍ ក្រសួងសុខាភិបាលសូមធ្វើការក្រើនរំឭកជាចុងក្រោយចំពោះ **លោក លោកស្រី ដែលជាម្ចាស់សេវាពិនិត្យព្យាបាលជំងឺឯកជនទាំងអស់** ចូលរួមសហការពង្រឹងបន្ថែមទៀត ក្នុងការអនុវត្តវិធានការក្នុងការទប់ស្កាត់ការឆ្លងរាលដាលនៃវីរុសកូវីដ-១៩ ទៅក្នុងសហគមន៍ ដោយអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវគោលការណ៍ណែនាំដូចខាងក្រោមនេះ ៖

1. មិនអនុញ្ញាតឱ្យធ្វើការពិនិត្យព្យាបាលអ្នកជំងឺសង្ស័យថាជាជំងឺកូវីដ-១៩ និងធ្វើតេស្តរកមេរោគកូវីដ-១៩ និងចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ជាដាច់ខាត (លើកលែងតែមានការការអនុញ្ញាតពីក្រសួងសុខាភិបាល)។
2. ត្រូវរៀបចំដាក់តុមួយ និងបុគ្គលិកគិលានុបដ្ឋាក-យិកា ០១រូប នៅពីខាងក្រៅច្រកទ្វារចូលទៅក្នុងកន្លែងពិនិត្យព្យាបាលអ្នកជំងឺ ដើម្បីរង់ចាំយកកំដៅ និងការបែងចែកជំងឺ (Triage) និងការត្រួតពិនិត្យអ្នកជំងឺដំបូង (Screening)។ គ្រប់ម្ចាស់សេវាពិនិត្យព្យាបាលជំងឺឯកជនទាំងអស់ ត្រូវធានាថាគ្រប់អ្នកជំងឺ និងមនុស្សចេញចូលទាំងអស់ដែលចូលទៅក្នុងកន្លែងពិនិត្យព្យាបាលជំងឺ ត្រូវបានត្រួតពិនិត្យតាមរយៈការវាស់កំដៅ ដោយប្រើឧបករណ៍ស្ទង់កម្តៅដែលមិនប៉ះផ្ទាល់ ដើម្បីពិនិត្យរកមើលពីករណីសង្ស័យជំងឺកូវីដ-១៩ ដោយពឹងផ្អែកលើនិយមន័យករណីដែលក្រសួងសុខាភិបាលបានកំណត់ និងធ្វើបច្ចុប្បន្នភាពជាប្រចាំ (ឧបសម្ព័ន្ធ១ ឧបសម្ព័ន្ធ២ ឧបសម្ព័ន្ធ៣ និងឧបសម្ព័ន្ធ២)។
3. ប្រសិនបើមានសញ្ញាណាមួយដូចក្នុងនិយមន័យកូវីដ-១៩ អ្នកជំងឺ ឬបុគ្គលនោះ សន្មត់ថាជាករណីសង្ស័យជំងឺកូវីដ-១៩ ត្រូវឱ្យគាត់ពាក់ម៉ាស់ និងណែនាំគាត់ឱ្យទៅកាន់កន្លែងរង់ចាំមួយដែលនៅក្បែរនោះ ដោយរក្សាគម្លាតយ៉ាងហោចណាស់មួយម៉ែត្រកន្លះ (១.៥ម៉ែត្រ) ពីគ្នា រួចជូនព័ត៌មានទៅកាន់មន្ទីរសុខាភិបាលរាជធានី-ខេត្ត ដើម្បីមកសម្របសម្រួលបញ្ជូនគាត់ទៅកាន់មណ្ឌលចត្តាឡីស័កដែលរៀបចំសម្រាប់អ្នកជំងឺកូវីដ-១៩។
4. ត្រូវអនុវត្តអនាម័យដៃជាប្រចាំ ដោយលាងដៃជាមួយសាប៊ូនិងទឹកស្អាត ឬអាល់កុល៧០% ឬអាល់កុលជែល។ ក្នុងករណីអ្នកជំងឺសង្ស័យថាជាជំងឺកូវីដ-១៩ ត្រូវសម្អាតទីកន្លែងពិនិត្យព្យាបាលជំងឺ ដោយប្រើអាល់កុល ៧០% ឬ សូលុយស្យុងអូសាវែលដែលមានកំហាប់ ០.១% លើផ្ទៃឧបករណ៍ដែលប្រើប្រាស់ឡើងវិញ និងសូលុស្យុងអូសាវែលដែលមានកំហាប់ ០.៥% លើផ្ទៃប្រឡាក់ផ្សេងៗ និងជូតសម្អាតឥដ្ឋ និងសូលុស្យុងអូសាវែលដែលមានកំហាប់ ០.០៥% សម្រាប់គ្រាំឧបករណ៍សម្ភារៈដែលប្រើប្រាស់ឡើងវិញ ព្រមទាំងបាញ់សម្លាប់មេរោគនៅក្នុងបរិវេណពិនិត្យព្យាបាលអ្នកជំងឺទាំងមូល។

5. ត្រូវធ្វើចត្តាឡីស័ករយៈពេល ១៤ថ្ងៃ និងយកសំណាកទៅពិនិត្យ និងតាមដានសុខភាពជាប្រចាំ ចំពោះគ្រូពេទ្យ និងបុគ្គលិកដែលបានប៉ះពាល់ជាមួយនឹងអ្នកជំងឺដែលសង្ស័យថាជាជំងឺកូវីដ-១៩ នោះ។
6. ត្រូវមានធុងពណ៌លឿង ដែលមានស្លាកសញ្ញាគ្រោះថ្នាក់ពណ៌ខ្មៅ សម្រាប់ដាក់សំណល់ឆ្លងរោគ និងសម្ភារៈអ្នកជំងឺដែលសង្ស័យថាជាជំងឺកូវីដ-១៩ ដូចជាម៉ាស់ពាក់ ក្រដាស់ជូតជាដើម។ បន្ទាប់មកត្រូវប្រមូលយកសំណល់ទាំងនោះទៅដុតកំទេចចោល ក្នុងឡដែលមានសីតុណ្ហភាពលើសពី ៨០០ អង្សាសេ ឡើងទៅ។
7. ម្ចាស់សេវាពិនិត្យព្យាបាលជំងឺឯកជនទាំងអស់ ត្រូវជួយអប់រំផ្សព្វផ្សាយអំពីវិធានការណ៍នៃការចម្លងជំងឺកូវីដ-១៩ ទៅដល់បុគ្គលិក អ្នកជំងឺ និងក្រុមគ្រួសារអ្នកជំងឺ ព្រមទាំងឱ្យគាត់ចូលរួមសហការទប់ស្កាត់ការរាតត្បាតនៃជំងឺកូវីដ-១៩ ដោយការលាងដៃជាមួយទឹក និងសាប៊ូ ឬអាល់កុលឱ្យបានញឹកញាប់ និងពាក់ម៉ាស់ ព្រមទាំងរក្សានូវគម្លាតសុវត្ថិភាពយ៉ាងតិចពី ១.៥ ម៉ែត្រ ឡើងទៅ និងត្រូវដោយអនុវត្តនូវវិធានការណ៍ ៣ ការពារ ៣ កុំ និង ២ ចូលរួម គឺ៖

ក. អនុវត្ត ៣ ការពារ
- ពាក់ម៉ាស់
- លាងដៃឱ្យបានញឹកញាប់
- គម្លាតសុវត្ថិភាពសង្គម និងគម្លាតសុវត្ថិភាពបុគ្គល ដោយចាប់ពី ១.៥ ម៉ែត្រ ឡើងទៅឱ្យបានគ្រប់គ្នា និងនៅគ្រប់ទីកន្លែង។

ខ. អនុវត្ត ៣កុំ
- កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល និងប្រើម៉ាស៊ីនត្រជាក់ច្រើនពេក រកកន្លែងមានខ្យល់ចេញចូលល្អ
- កុំទៅកន្លែងមនុស្សច្រើនកុះករ
- កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា កុំកៀកស្មាគ្នា កុំឱបគ្នាជាដើម ពេលជួបគ្នា អ្នកមានផ្តាសាយ ឬសង្ស័យមានជំងឺកូវីដ-១៩ កុំចេញក្រៅ ហើយត្រូវទាក់ទងទៅគ្រូពេទ្យ ឬ ហៅទៅលេខ ១១៥។

គ. អនុវត្ត ២ ចូលរួម
- ចូលរួមក្នុងយុទ្ធនាការទទួលការចាក់វ៉ាក់សាំងប្រឆាំងកូវីដ-១៩
- ប្រើ QR Code Stop Covid ដើម្បីទប់ស្កាត់រោគរាតត្បាត។

ក្នុងករណីដែល **លោក លោកស្រី ដែលជាម្ចាស់សេវាពិនិត្យព្យាបាលជំងឺឯកជន** ណាមួយមិនបានគោរពទៅតាមការណែនាំរបស់ក្រសួងសុខាភិបាលទេនោះ ក្រសួងនឹងមានវិធានការយ៉ាងម៉ឹងម៉ាត់បំផុតចំពោះម្ចាស់សេវាពិនិត្យព្យាបាលជំងឺឯកជននោះ ដោយអនុវត្តទៅតាមច្បាប់ និងអនុក្រឹត្យ ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀតជាធរមានរួមមាន៖

- ការព្យួរ ឬដកអាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាតប្រកបអាជីវកម្ម
- ការបិទអាជីវកម្ម
- ពិន័យអន្តរការណ៍
- ពិន័យជាប្រាក់
- ទោសដាក់ពន្ធនាគារ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើនេះ សូម **លោក លោកស្រី ដែលជាម្ចាស់សេវាពិនិត្យព្យាបាលជំងឺឯកជនទាំងអស់** ត្រូវអនុវត្តទៅតាមការណែនាំខាងលើនេះដោយស្មារតីទទួលខុសត្រូវខ្ពស់បំផុត។

សូម **លោក លោកស្រី ដែលជាម្ចាស់សេវាពិនិត្យព្យាបាលជំងឺឯកជនទាំងអស់** ទទួលនូវការរាប់អានអំពីខ្ញុំ។

ជ.រដ្ឋមន្ត្រី
រដ្ឋលេខាធិការ

វេជ្ជ. ឱ វណ្ណឌីន

**ចម្លងជូន:**
-ខុទ្ទកាល័យក្រសួងសុខាភិបាល
-រដ្ឋបាលរាជធានី-ខេត្ត
(ដើម្បីជូនជ្រាបជាព័ត៌មាន)
-មន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានី ខេត្ត
(ដើម្បីអនុវត្តន៍)
-ឯកសារ-កាលប្បវត្តិ